## មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)


# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ែម តំបន់ទី ៨

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃពុធ ទី០៧ ខែកុម្ភៈ ឆ្នាំ២០០៧**

**ខេត្តឧត្តរមានជ័យ**

## ខប់សែល ដំណាក់កាលទី ២

## COPCEL Phase II


*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

០១.ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក **ដួង វីរ័ត្ន** ប្រធានកម្មវិធីសន្តិសុខមនុស្ស និងការកសាងសន្តិភាព និងជាតំណាង លោក **ឡារី ស្ត្រេន្ជ (Larry Strange)** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

០២.បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

០៣.ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយ លោក **ជិញ សំភូ** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តឧត្តរមានជ័យ

០៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទ ខេត្តឧត្តរមានជ័យ

០៥. សេចក្តីផ្សេងៗ

### ០១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ដួង វីរ័ត្ន ប្រធានកម្មវិធី សន្តិសុខមនុស្ស និងការកសាងសន្តិភាព និងជាតំណាង លោក ឡារី ស្ត្រេន្ជ (Larry Strange) នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **ដួង វីរ័ត្ន** ប្រធានកម្មវិធីសន្តិសុខមនុស្ស និងការកសាងសន្តិភាព ក្នុងនាមជាតំណាង **លោក ឡារី ស្ត្រេន្ជ** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានធ្វើការស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិកនៃអង្គប្រជុំទាំងមូល ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនាព្រឹកនេះ ដែលបានរៀបចំឡើងនៅក្នុងមន្ទីអប់រំយុវជន និងកីឡា ។ លោក ក៏សូមថ្លែងអំណរគុណដល់ ឯកឧត្តម ពេជ្រ សុ ភិន អភិបាលខេត្តឧត្តរមានជ័យ ដែលបានគាំទ្រយ៉ាងពេញទំហឹង និងជួយសំរួលរាល់ការងាររបស់ វិទ្យាស្ថាន CDRI ដើម្បីឱ្យមានការរៀបចំកិច្ចប្រជុំនេះឡើង ហើយ លោក សូមថ្លែងអំណរគុណចំពោះ លោក **ជិញ សំភូ** ដែលបានចូលរួមគាំទ្រ យ៉ាងសកម្មក្នុងការកម្មវិធីនាព្រឹកនេះ ឆ្លៀតក្នុងឱកាសនេះ លោក សូមថ្លែងអំណរគុណជាពិសេសដល់កម្មវិធីអភិវឌ្ឍន៍របស់អង្គការ សហប្រជាជាតិ (UNDP) ដែលបានគាំទ្រយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនេះតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ខេត្ត ។ លោក សូមជូនពរឱ្យកិច្ចប្រជុំទទួលបាននូវផ្លែផ្កា ព្រមទាំងមានការពិភាក្សាយ៉ាងផុលផុស បើកចំហរ និងយោគយល់គ្នាជាទីបំផុតពីសំណាក់អង្គប្រជុំទាំងមូល ។

### ០២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយ លោក ឱក សេរី សោភ័ក្តិ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ខប់សែល នៃវិទ្យាស្ថាន CDRI

លោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែលបានលើកឡើងពីប្រវត្តិដើមទាក់ទង នឹងយន្តការខប់សែល ពីភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ ដែលបានរងនូវភាពខ្ទេចខ្ទាំដោយសារសង្គ្រាម ដែលរូប លោក ផ្ទាល់ក៏បានចូលរួមតស៊ូតាមជាយដែន ក្នុងការប្រយុទ្ធតស៊ូនៅតាមជាយដែនពីឆ្នាំ ១៩៨១ ដល់ឆ្នាំ ១៩៩២ ។ ក្នុងកិច្ចប្រជុំពេលនេះដែរមានមួយ ចំនួនដែល លោក ធ្លាប់ស្គាល់ក្នុងអំឡុងពេលតស៊ូការពារតាមជាយដែននៅភូមិរការ ខេត្តឧត្តរមានជ័យ គឺនៅពេលនោះហើយដែលប្រទេសកម្ពុជាយើងឆ្លងកាត់នូវសង្គ្រាម ២៨ឆ្នាំ ហើយក្មេងៗដែលធំដឹងក្តីឡើង គឺសុទ្ធតែបានឆ្លងកាត់សង្គ្រាម ។ លោក បាន បន្ថែម

ទៀតថា ការកសាងប្រទេសជាតិមានតែពីរផ្លូវទេតាមតែយើងបានដឹង គឺផ្លូវប្រើកំលាំង និងអំណាច និងការរួមគ្នាកសាងតាមលទ្ធិប្រជាធិបតេយ្យ ។ ប្រទេសយើងបានឆ្លងកាត់សង្គ្រាមជាច្រើនជំនាន់ដែលធ្វើឱ្យ ធ្វើឱ្យប្រជាជនរស់នៅក្នុងភាពសោក សៅ និងការមើលងាយពីប្រទេសជិតខាង ។ ដូចនេះហើយបានជាគូភាគីទាំងអស់សម្រេចចិត្តបោះបង់ចោលនូវផ្លូវដ៏ជូចត់នេះ ហើយ ចាប់គ្នាកសាងសន្តិភាព និងការអភិវឌ្ឍន៍ ។ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ ដោយមានការស្នើពីសម្តេច ហ៊ុន សែន និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង ឱ្យចូលរួមនៅក្នុងរាជរដ្ឋាភិបាល ។ ហើយ លោក បានធ្វើជាទីប្រឹក្សា និងជានាយខុទ្ទកាល័យរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង នៅឆ្នាំ ១៩៩៣ ។ លោក បានចំណាយពេល ៥ឆ្នាំ ក្នុងការធ្វើការនោះនៅក្នុងរយៈពេល ៥ឆ្នាំ នោះរាជរដ្ឋាភិបាលបានប្រគល់ ភាកិច្ចរៀបចំការ បោះឆ្នោតឆ្នាំ ១៩៩៨ ដើម្បីរៀបការបោះឆ្នោតដោយខ្លួនឯង ។ ប្រទេសយើងចាប់ផ្តើមរៀបចំការបោះឆ្នោតនេះតាំងពីឆ្នាំ ១៩៩៤ មកម្លេះ មួយឆ្នាំ គឺក្រោយពេលដែលអ៊ុនតាក់រៀបចំឱ្យ យើងបានរៀបចំភ្លាមដោយសារយើងត្រូវរៀនសូត្រច្រើនណាស់អំពីការបោះឆ្នោតទី បំផុតយើងក៏បានឈានទៅរកការបោះឆ្នោតឆ្នាំ ១៩៩៨ ។ ពេលនោះហើយដែល លោក គិតថា ការបោះឆ្នោតដែលពោរពេញទៅដោយទំនាស់នេះ គឺនៅពេលណាមួយយើងត្រូវតែអាចដោះស្រាយទំនាស់នៅក្នុងការបោះឆ្នោតនៅប្រទេសកម្ពុជាបានដោយខ្មែរខ្លួនឯង ។

នៅឆ្នាំ ១៩៩៩ លោក គិតតថា ៥ឆ្នាំធ្វើការជាមួយរដ្ឋ ៥ឆ្នាំធ្វើការក្រៅរដ្ឋ ៥ឆ្នាំ ធ្វើការជាទីប្រឹក្សាឱ្យអង្គការអន្តរជាតិធំៗ លោក ក៏បាលាលែងពីដំ ណែងពីក្នុង ជួររដ្ឋាភិបាល ។ បន្ទាប់មក លោក បានធ្វើការឱ្យវិទ្យាស្ថាន CDRI ក្នុងឋានៈជាអ្នកសម្របសម្រួលក្នុងកម្មវិធីដើម្បីអភិវឌ្ឍន៍ និងសន្តិភាព នៅពេលនោះ លោក បានធ្វើការស្រាវជ្រាវមួយថា តើការបោះឆ្នោតឆ្នាំ ១៩៩៨ ហេតុអ្វីបានជាមានអំពើហិង្សាច្រើនកើតឡើង? ហើយក្នុងឆ្នាំ ១៩៩៩ នេះដែរ លោក ក៏បានគិតឃើញហើយបង្កើតយន្តការ ខបសែលនេះឡើង ដែលជាយន្តការបង្ការទំនាស់ដោយយកគូរភាគីទាំងអស់ដែលពាក់ព័ន្ធ នឹងការបោះឆ្នោតយកមកជជែកគ្នាត្រង់ ទៅត្រង់មកបង្កើតនូវបរិយាកាសទំនុកចិត្តគ្នាមួយ ហើយបង្កើតវប្បធម៌មួយជជែកគ្នាត្រង់ទៅត្រង់មកដោយអហឹង្សា ។ ក្នុងឆ្នាំនោះ ដែរ លោក ក៏បង្កើតកម្មវិធីបណ្តុះបណ្តាលកម្មវិធីបង្ការ និងដោះស្រាយទំនាស់ និងគ្រប់គ្រងទំនាស់ជាច្រើនលើកច្រើនសារនៅអន្លង់ វែង នឹងត្រពាំងប្រសាទ ដែលមានការគាំទ្រពី លោក អភិបាលស្រុកអន្លង់វែង និងត្រពាំងប្រាសាទ កម្មវិធីនេះធ្វើជាពិសេសនៅតំបន់សមារហរណកម្ម ឥលូវនេះយើងក្លាយជាសង្គមជាតិ និងជាគ្រួសារតែមួយ ហើយបង្កើតជាយន្តការ ខប់សែល នេះឡើង នៅពេលនោះ យើង ធ្វើការប្រជុំចំនួន ៥០ដង ក្នុងរយៈពេល ៤ឆ្នាំ ដែលសុទ្ធសឹងជាការប្រជុំថ្នាក់ជាតិ ។ លោក បានបន្ថែមទៀតថា អន្តរជាតិបានទទួលស្គាល់ថា ប្រទេសកម្ពុជាជាប្រទេសដែលចេញពីសង្គ្រាម ២៨ឆ្នាំ ហើយចេះរកឃើញយន្តការនេះដោយខ្លួនឯង ហើយយន្តការ ខប់សែលនេះ គឺកើតឡើងដោយដៃខ្មែរសុទ្ធសាធ មិនមានបរទេសចូលរួមទេ នេះគឺជាមោទនៈភាពមួយដែលយើងអាចរួបរួមគ្នាបានមិនដូចប្រទេសមួយចំនួនដូចជាប្រទេសអាហ្វ្រិក អាមេរិកឡាទីន ។ នៅពេលដែលចប់យន្តការនេះនៅឆ្នាំ ២០០៣ អង្គការសហប្រជាជាតិ UNDP នៅទីក្រុងញូយ៉កបានមើលឃើញរបាយការណ៍នេះ ហើយបានមកជួប លោក **ឡាវី ស្រេ្តន** និងរូប លោក ដើម្បីពិភាក្សា ហើយគេបានកោតសរសើរ ថា យន្តការនេះល្អបន្ទាប់មកគេក៏ផ្តល់ជំនួយហិរញ្ញវត្ថុជាច្រើនដើម្បីឱ្យបន្តយន្តការនេះឡើងវិញដើម្បីបម្រើការបោះឆ្នោត ២០០៧ និង ២០០៨ ។ លោក បានបន្តទៀតថា ការប្រជុំនៅថ្នាក់ជាតិជាការល្អប្រសើរហើយ ប៉ុន្តែទំនាស់ពិតប្រាកដដែលសំខាន់ គឺកើតឡើងនៅថ្នាក់មូលដ្ឋាន បើសិនយើងក្តាប់ ឬគ្រប់គ្រងទំនាស់ទាំងអស់នេះបាន ជាពិសេសនៅថ្នាក់ភូមិ ឃុំ រឿងទាំងអស់មិនបណ្តាលឱ្យមាន ទំនាស់ដល់ថ្នាក់លើទេ ។ ដោយមើលឃើញពីសារៈសំខាន់នេះ ទើបយើងបង្កើតអោយមាន ខប់សែលប្រ៉ម នេះឡើង ដែលបានទាញយកវប្បធម៌ នៃការជជែកពិភ្សាគ្នាពីថ្នាក់ជាតិទៅថ្នាក់ខេត្ត ដែលយើងមានការ

ចូលរួមជាពិសេសពី ឃុំដែលតំណាងឱ្យគណបក្សនិមួយៗចំនួន ១២នាក់ មកចូលរួមគ្រប់ខេត្តទាំងអស់មានទាំងមេភូមិ សង្គមស៊ីវិល និងប្រធានមន្ទីដែលបានចូលរួមផងដែរនៅ ក្នុងវិទ្យាស្ថាន CDRI ។ មិនមានកម្មវិធីណាដែលមានធ្វើគ្រប់ខេត្តទាំងអស់ និងក្នុង ១ខេត្ត ធ្វើឡើង ២ដង ទេ ក្នុងរយៈពេលប៉ុន្មាន ឆ្នាំនេះ ខប់សែល និងធ្វើឡើងចំនួន ៤៨ដង ។ លោក បានបន្តថា អ្នកស្រី Margie Cook ប្រធាន ខាងអភិបាលកិច្ចនៅ UNDP ក៏បានចូលរួម ខប់សែលប្រ៉ូម នៅខេត្តសៀមរាមបានថ្លែងដោយត្រង់ៗជាសាធារណៈថា មានប្រទេសមួយបានសរសេរលិខិតមក UNDP ផ្ទាល់ដើម្បីសិក្សារៀនសូត្រអំពីយន្តការខប់សែល ពីប្រទេសកម្ពុជាដើម្បីយកទៅ អនុវត្តន៍នៅក្នុងប្រទេសរបស់គេដែលទើបងើបចេញ ពីសង្គ្រាមដូចជាប្រទេសយើងដែរ ។ ហើយក្នុងពេលប៉ុន្មានឆ្នាំនេះប្រទេស អាហ្វហ្គានីសស្ថាន ប្រទេសទីម័រខាងកើត ក៏បានមកជួប លោក ផ្ទាល់ដើម្បីរៀនសូត្រ ដូច្នេះគោលបំណងរបស់ ខប់សែល គឺចង់ឱ្យ រូបភាពរបស់ប្រទេសកម្ពុជា ដែលធ្លាប់តែមានភាពខ្មៅងងឹង និងរូបភាពហឹង្សាការកាប់សម្លាប់គ្នាឯងអោយផុតរលត់ទៅ ហើយបង្ហាញ ថា កម្ពុជាយើងចេះជជែកពិភាក្សាគ្នាដោយសន្តិវិធី ដោយថ្លៃថ្នូរ និងមានឥរិយាបទគោរពគ្នាទៅវិញទៅមក មិនមែនតែនៅលើថ្នាក់ ជាតិនោះទេ គឺមានទាំងនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន លោក បានបន្ថែមទៀតថា ទាំងអស់នេះកាលពីមុនគ្រាន់តែជាការស្រមៃរបស់ លោក ទេ ប៉ុន្តែឥឡូវនេះវាក្លាយជាពិតហើយ ។ យន្តការខប់សែលប្រ៉ូម និងខប់សែលនៅថ្នាក់ជាតិមានគោលដៅធំៗ ៣ៈ

**ទី១** ជួយ គ.ជ.ប និង រាជរដ្ឋាភិបាលជាពិសេសក្រសួងមហាផ្ទៃធ្វើយ៉ាងណាធ្វើឱ្យការពិនិត្យចុះឈ្មោះបោះឆ្នោតឱ្យក្លាយជា ទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាឱ្យតែដល់ពេលបោះឆ្នោតប្រជាពលរដ្ឋដែលមានអាយុគ្រប់ ១៨ឆ្នាំ ទៅសាលាឃុំដើម្បីចុះឈ្មោះបោះ ឆ្នោត និងដើម្បីមើលឈ្មោះរបស់ពួកគេតើមាន ឬ អត់ ។ ម្យ៉ាងវិញទៀតរឿងសរសេរឈ្មោះត្រូវសរសេរឱ្យមានលក្ខណៈត្រឹមត្រូវ និងឈប់ដូរឈ្មោះទៀតទៅពេលដែលចុះទៅតាមឃុំមានការលំបាកដោយសារតែប្រជាពលរដ្ឋ លោក ដូរឈ្មោះច្រើន សំបុត្រកំណើតខុសពីអត្តញ្ញាណប័ណ្ណ អត្តញ្ញាណប័ណ្ណខុសពីឈ្មោះអត្រានុគោលដ្ឋាន ។ ដូច្នេះយើងត្រូវបង្ហាត់ប្រជាពលរដ្ឋយើងឱ្យឈប់ ប្រើវិធីនេះទៀតទៅ និងគ្រប់តំណាងរដ្ឋបាលនៅគ្រប់ជាន់ថ្នាក់នៅពេលដែលសរសេរឈ្មោះ ពីមុនយើងឃើញថា មានការសរសេរខុស ច្រើនស្ទើតែគ្រប់ជាន់ថ្នាក់ ឥលូវនេះយើងកំពុងតែធ្វើការកែតម្រូវបានហើយ ហើយ UNDP កំពុងតែរកវិធីជួយរដ្ឋាភិបាលព្រោះ ឈ្មោះស្ទួនច្រើន អញ្ចឹងយើងធ្វើយ៉ាងណាលុបបំបាត់ឈ្មោះស្ទួនដែលមានរាប់សែននាក់នោះចោល ។

**ទី២** ដោយសារតែច្បាប់បោះឆ្នោតលើកនេះបានចែងថា មានតែអត្តសញ្ញាណប័ណ្ណទើបអាចបោះឆ្នោតបាន ដូច្នេះបានជា ខប់សែល បានធ្វើការជាមួយក្រសូងមហាផ្ទៃដើម្បីសូមធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំ បានទទួលអត្តសញ្ញាណ ប័ណ្ណគ្រប់ៗគ្នា និងបានទទួលដោយរាជរដ្ឋាភិបាលប្រកាសជាសាធារណៈកុំឱ្យមានអស់លុយអស់កាក់ ដូច្នេះហើយបានជា ឯកឧត្តមឧបនាយករដ្ឋមន្រ្តី និងរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ **ស ខេង** លោក បើកយុទ្ធនាការឆ្នាំ ២០០៦ ជាយុទ្ធនាការគំហុគមួយ គឺក្នុង១ឆ្នាំធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលមិនទាន់បានទទួល អត្តសញ្ញាណប័ណ្ណ ១លាន៩សែន នាក់សូមឱ្យបានទទួលទាំងអស់គ្នា ។ តាម ខប់សែល ដឹងលទ្ធផលទោះមិនបាន ១០០% ក៏ ៩៥% នៃប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើង គឺបានទទួលអត្តសញ្ញាណប័ណ្ណគ្រប់គ្នា ហើយយើងគិតថា ក្នុងតែមួយឆ្នាំ ២០០៧ នេះទៀត នឹងធ្វើយ៉ាងណារួមគ្នាជាមួយ និង NEC វិទ្យាស្ថាន CDRI និងក្រសួងមហាផ្ទៃ ដើម្បីឱ្យ ប្រជាពលរដ្ឋខ្មែរមានអត្តសញ្ញាណប័ណ្ណ គ្រប់ៗគ្នាតែម្តង ។ បន្ទាប់មកយើង នឹងធ្វើការអប់រំដល់ប្រជាពលរដ្ឋរបស់យើងសូមអង្វរ លោក ឱ្យឈប់ដូរឈ្មោះទៅព្រោះដល់ពេលទៅធ្វើអត្តសញ្ញាណប័ណ្ណដាក់ឈ្មោះ ផ្សេងនាំឱ្យអាជ្ញាធរខេត្ត, ស្រុកវង្វេងវង្វាន់អស់ហើយ សូមឱ្យយើងមានការប្រយត្ន័នូវអក្ខរាវិរុធឈ្មោះរបស់យើង ព្រោះកន្លងមកយើង មិនសូវយកចិត្តទុកដាក់ទេចំពោះបញ្ហាហ្នឹង ។ ដូច្នេះ ខប់សែល សង្ឃឹមថាប៉ុន្មានឆ្នាំទៅមុខទៀតបញ្ហាអត្តសញ្ញាណប័ណ្ណលែងចោទជា

បញ្ហាទៀតនៅក្នុងប្រទេសកម្ពុជាយើង ព្រោះនៅក្នុងប្រទេសនិមួយៗពេលយើងកើតជាពលរដ្ឋដល់អាយុ ១៨ឆ្នាំ បញ្ហាអត្តសញ្ញាណប័ណ្ណ គឺជាបញ្ហាមូលដ្ឋានតែម្តង កាលណាគ្មាន អត្តសញ្ញាណប័ណ្ណយើងមិនអាចរៀន, ធ្វើការ, បើកលុយ ឬធ្វើអ្វីផ្សេងៗទៀតបានទេ វាហាក់ដូចជាយើងគ្មានរូបនៅក្នុងទឹកដីនោះអញ្ចឹង ដូច្នេះហើយបានជាយើងជុំរុញបញ្ហាហ្នឹងសំខាន់ណាស់ដើម្បីឱ្យប្រជាពលរដ្ឋមានអត្តសញ្ញាណប័ណ្ណគ្រប់ៗគ្នា ។

**ទី៣** ធ្វើយ៉ាងណាឱ្យយុទ្ធនាការបោះឆ្នោតម្តងៗប្រកបដោយសុវត្ថិភាព ជាយន្តការមួយប្រកបដោយសន្តិភាពអហឹង្សា ជាយន្តការមួយដែលអ្នកឈ្នះឆ្នោតឈ្នះនៅក្នុងភាពមិនមានមន្ទិលឈ្នះដោយប្រជាពលរដ្ឋ លោក បោះឱ្យមិនមែនឈ្នះក្នុងបរិយាកាសភ័យ ។

## ០៤. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតថ្លែងដោយលោក ខិញ សំភូ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តឧត្តរមានជ័យ

លោក បានស្វាគមន៍អង្គប្រជុំទាំងមូល និងសូមថ្លែងអំណរគុណចំពោះ លោក **ឡាវី ស្រ្តេន** ជានាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ព្រមទាំង លោក ដួង វីរ័ត្ន ដែល បានអញ្ជើញ លោក ឱ្យចូលរួមក្នុងកិច្ចប្រជុំ ខមសែសប្រ៉ម នេះ ។ លោក បានលើកឡើងអំពីស្ថានភាពទូទៅនៃការបោះឆ្នោតនៅ ក្នុងខេត្តឧត្តរមានជ័យពេលនេះ និងពេលអនាគត់ដែលមាន ១២ចំនុច ដូចតទៅ:

**ទី១** ភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ ស្ថិតនៅភាគឧត្តរនៃប្រទេសមានចំងាយ ៤៦៩ គីឡូម៉ែត្រពីរាជធានីភ្នំពេញមាន ៥ស្រុក ៤ឃុំ ២៣២ភូមិ និងមានការិយាល័យសរុបចំនួន ១៦៩ការិយាល័យបោះឆ្នោត នាឆ្នាំមុន លោក បាននិយាយថា នៅ ខេត្តឧត្តរមានជ័យចំនួន ១៦១ការិយាល័យបោះឆ្នោត ចុះនៅឆ្នាំ ២០០៦ កន្លងមកនេះ ការិយាល័យភ្លោះដែលមានចំនួនប្រជាពលរដ្ឋលើសចំនួន ៧០០ មានចំនួន ៨ការិយាល័យបោះឆ្នោត ដែលគណកម្មធិការជាតិរៀបចំការបោះឆ្នោត បានប្តល់លេខកូដដើម្បីឱ្យបង្កើតការិយាល័យថ្មី ។ ខេត្តឧត្តរមានជ័យ មានផ្ទៃក្រឡាប្រមាណ ៦១៥៨គីឡូម៉ែត្រការេ មានប្រជាជនសរុម ១៤៧ពាន់ ៥២២នាក់ មានអាយុ ១៨ឆ្នាំ ឡើង ៧៨ពាន់២៤៥នាក់ស្រីចំនួន ៣៨០៣១ ។ ប្រជាជនមានឈ្មោះបោះឆ្នោតក្នុងឆ្នាំ ២០០៧ ខាងមុខនេះសរុប ៨៦០៤៥០នាក់ ។

**ទី២** ដំណើរការបោះឆ្នោតនៅកម្ពុជា ក្រោយពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ប្រទេសកម្ពុជាបានកែប្រែរបបនយោបាយ និងបាវចនាជាតិប្រកាន់របបរាជានិយមប្រកាន់រដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យពហុបក្ស ហើយបានរៀបចំការបោះឆ្នោតចំនួន ៥លើករួចមកហើយ គឺការបោះឆ្នោតជាសកលចំនួន ៤លើក និងអសកលចំនួន ១លើក ។ នៅឆ្នាំ ១៩៩៣ គឺជាការបោះឆ្នោតនាទិការទី១ ជ្រើសតាំងដំណាងរាស្ត្រដែលរៀបចំដោយអ៊ុនតាត់ ។ នៅឆ្នាំ ១៩៩៨ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាសកលជ្រើសតាំងដំណាងរាស្ត្រនាទិការទី២ ដែលរៀបចំដោយកម្ពុជាខ្លួនឯង ។ ក្នុងការបោះឆ្នោតទាំងពីរលើកនេះ ខេត្តឧត្តរមានជ័យ គ្រាន់តែជាខេត្តមួយចំណុះឱ្យខេត្តសៀមរាបប៉ុណ្ណោះក្នុងការបោះឆ្នោតមានការលំបាកជាច្រើនដូចជាសង្គ្រាមស៊ីវិលក្នុងស្រុក អសន្តិសុខ ចោរកម្ម និងការភ័យខ្លាច ប៉ុន្តែបញ្ហាទាំងអស់នេះមិនអាចរាំងស្ទះនូវការបោះឆ្នោតឡើយ ហើយលទ្ធផលអាចទទួលយកបាន ។ នៅក្នុងឆ្នាំ ២០០២ នៅថ្ងៃទី១ ខែកុម្ភៈ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតឃុំសង្កាត់នាទិការទី១ ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ និងការគ្រប់គ្រងរដ្ឋបាលវិមជ្ឈការ និងសហវិមជ្ឈការក្នុងថ្នាក់មូលដ្ឋាន ក្នុងពេលនោះ ខេត្តឧត្តរមានជ័យ ត្រូវបានបង្កើតឡើងស្របពេនោះ ខេត្តឧត្តរមានជ័យបានដំណើរការការងាររដ្ឋបាលក្នុងឆ្នាំ ១៩៩៩ ។ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត ៦៩៩៩៧នាក់ បានចុះឈ្មោះបោះឆ្នោត ៤៣៨១៥នាក់ ក្នុងនោះស្រី ២២៨៨៤នាក់ គិតជាភាគរយនៃ

ការចុះឈ្មោះ ៧៦.៨៦ភាគរយ នៅ ខេត្តឧត្តរមានជ័យ មានការិយាល័យបោះឆ្នោតចំនួន ១៣២ការិយាល័យ ហើយចំនួនប្រជាពលរដ្ឋទៅចូលរួមបោះឆ្នោតចំនួន ៣៦៦៩៤នាក់ គិតជាភាគរយ ៨៣.៧៥ភាគរយ ។ នៅក្នុងឆ្នាំ ២០០៣ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាសកលជ្រើសតាំងដំណាងរាស្ត្រនាទិការទី ៣ នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៣ ។ ខេត្តឧត្តរមានជ័យ មានការិល័យចេះតែកើនឡើងរហូតដល់ ១៤២ការិយាល័យ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតចាប់ពីអាយុ ១៨ឆ្នាំ ឡើងមានចំនួន ៦២៣៤៦នាក់ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៥៧៤៣០នាក់ គិតជាភាគរយស្មើនឹង ៩២.១១% ប្រជាពលរដ្ឋបានទៅបោះឆ្នោតសរុប ៤៣៦៤៨នាក់ គិតជាភាគរយស្មើនឹង ៧៦.០៧% ។ ក្នុងការបោះឆ្នោតឆ្នាំ ២០០២ និងឆ្នាំ ២០០៣ ខាងលើ មានភាពងាយស្រួលដោយសារសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ជាស្ថាពរ វិច្ឆេដកម្ម ចោរកម្ម ត្រូវបានថយចុះគួរឱ្យគត់សំគាល់ ។ នៅថ្ងៃទី ២២ ខែ មករា ២០០៦ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាអសកល គឺការបោះឆ្នោតព្រឹទ្ធសភានាទិកាលទី២ ។ ខេត្តឧត្តរមានជ័យ ស្ថិតក្នុងភូមិភាគ ៤ ដែលរួមបញ្ចូលគ្នា ៥ខេត្តក្រុងរួមមាន ខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន ដែលមាន ១០អសនៈ ក្នុងនោះ ខេត្តឧត្តរមានជ័យមានតែ ១ការិយាល័យប៉ុណ្ណោះ ដែលមានលេខកូដ ៤០០៦ អ្នកចុះឈ្មោះបោះឆ្នោតមានចំនួន ១៥១នាក់ ក្រុមប្រឹក្សា ភូមិចំនួន ១៥០នាក់ និងតំណាងរាស្ត្រម្នាក់ ។ អ្នកបោះឆ្នោតមាន ១៥០នាក់ ស្មើនឹង ១០០% ការបោះឆ្នោតមានភាពងាយស្រួលដោយ សារការិយាល័យមានតែមួយ និងអ្នកបោះឆ្នោតមានចំនួនតិច ស្ថានភាពនយោបាយមានលក្ខណៈល្អប្រសើរ បញ្ហាសន្តិសុខ និងសុវត្ថិភាពត្រូវបានធានាទាំងស្រុង ។ បញ្ហាវិវាទ ការគំរាមកំហែង ក្នុងដំណើរការបោះឆ្នោតកើតមានឡើងក្នុងដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាទិកាលទី ១ ឆ្នាំ ២០០២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាទិកាលទី៣ ក្នុងឆ្នាំ ២០០៣ ខេត្តឧត្តរមានជ័យ មានបញ្ហាដូចជា ការទម្លាក់ផ្លាកគណបក្សនយោបាយជាច្រើនលើកច្រើនសារទៅលើផ្លាក គណបក្ស សម រង្ស៊ី និង គណបក្ស ហ្វ៊ុន ស៊ីនប៉ិច នៅក្នុងស្រុក អន្លង់វែង និង ស្រុកត្រពាំងប្រសាទ ការគំរាមកំហែងបង្ករឱ្យមានការវិវាទកើតឡើងពីសំណាក់សមាជិកសកម្មគាំទ្រគណបក្សនយោបាយមួយ ទៅលើគណបក្សនយោបាយមួយទៀត ។ ដំណោះស្រាយបញ្ហាទាំងពីរខាងលើនេះ គណកម្មការខេត្តរៀបចំការបោះឆ្នោត និងគណកម្មការឃុំ-សង្កាត់ រៀបចំការបោះឆ្នោត បានចាត់វិធានការចុះស្រាវជ្រាវស៊ើបអង្កេតគ្រប់ករណី រួមសហការជាមួយអាជ្ញាធរដែនដី និងកំលាំងមានសមត្ថកិច្ច ។ បញ្ហាមួយចំនួនត្រូវបានដោះស្រាយដោយសន្តិវិធី និងមានតម្លា ភាពចប់ជាស្ថាពរដោយមានការសុខចិត្តទទួលយកដំណោះស្រាយរវាងភាគីវិវាទទាំងពីរ បញ្ហាមួយចំនួនដែលនៅសេសសល់មិនទាន់ បានដោះស្រាយ PEC បានបំបែកសុំនុំរឿងជូនអាជ្ញាធរមានសមត្ថកិច្ចបន្តស្រាវជ្រាវ និងស៊ើបអង្កេតក្រោយ ។ មានពាក្យបណ្តឹងមួយចំនួនត្រូវបានដាក់នៅ គ.ជ.ប ហើយ គ.ជ.ប បានបញ្ជូនបណ្តឹងទាំងនោះមក PEC វិញ ពាក្យបណ្តឹងមួយ ចំនួនទៀតបានដាក់នៅ PEC ផ្ទាល់ដើម្បីដោះស្រាយផ្ទាល់ក្រោយពីបានសិក្សាស្រាវជ្រាវឃើញ ។ លោកបានបន្តថា ដើមហេតុនៃបណ្តឹងមួយចំនួន ស្វែងរកមិនឃើញដើមចោទ និងចុងចោទទេព្រោះករណីទាំង នោះកើតឡើងជាច្រើនខែហើយ អង្គហេតុទាំងនោះត្រូវបានផ្លាស់ប្តូរ ទីលំនៅទៅកាន់ស្រុកផ្សេងៗខេត្តផ្សេងៗទៀត ។

**ទី៣** ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ផលលំបាក បញ្ហាផ្សេងៗ និងដំណោះស្រាយ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ការចុះឈ្មោះឆ្នោតកន្លងមកចាប់ដំណើរការពីការបោះឆ្នោតតំណាងរាស្ត្រនាទិការទី ១ ទី ២ នៅឆ្នាំ ១៩៩៨ និងការបោះឆ្នោតជ្រើសរើសក្រុមព្រឹក្សាឃុំសង្កាត់នាទិការទី ១ ឆ្នាំ២០០២ និតិវិធីនៃការចុះឈ្មោះ អ៊ុនតាក់ គឺ គ.ជ.ប បានបង្កើតមន្ត្រីការិយាល័យសម្រាប់ចុះឈ្មោះបោះឆ្នោតតាមបណ្តាឃុំនិមួយៗ ដើម្បីរៀបចំការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋដោយឡែកចាប់ពីឆ្នាំ ២០០៣ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រីនាទិការទី ៣ រហូតដល់ឆ្នាំ ២០០៦ រយៈពេល ៤ឆ្នាំ កន្លងមក

គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចដល់ក្រុមព្រឹក្សាឃុំ ស្មៀនឃុំ អនុវត្តន៍ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតទៅតាមឃុំសាថ្មីដើម្បីធ្វើបញ្ជីបច្ចុប្បន្ន ភាព បញ្ជីបោះឆ្នោតឱ្យមានសុក្រឹតភាព ។ លទ្ធផលនៃការពិនិត្យការចុះឈ្មោះបោះឆ្នោត ២ឆ្នាំចុងក្រោយឆ្នាំ ២០០៥ និង ២០០៦ ។ លទ្ធផលចុះឈ្មោះឆ្នាំ ២០០៥ ការិយាល័យមានចំនួនសរុបកើតឡើង ១៥៥ការិយាល័យ ប្រជាពលរដ្ឋសរុប ១៤០៨១២នាក់ អាយុ ១៨ឆ្នាំឡើង ៧០៩១២នាក់ ស្រ្តីចំនួន ៣៦៣៦៦នាក់ ។ ឈ្មោះក្នុងបញ្ជីក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៤ ចំនួន ៦៣៤៤០នាក់ ចុះឈ្មោះថ្មី ៦០៩៧នាក់ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំនួន១០៨២នាក់ ឈ្មោះក្នុងឆ្នាំ ២០០៥ សរុប ៦៨៤៧៧នាក់ គិតជាភាគរយ ៩៦.៥៧ % ក្នុងនោះស្ត្រី ចំនួន ៣៥២៦៩នាក់ គិតជាភាគរយ ៥១.៥០% ។ លទ្ធផលបោះឆ្នោតឆ្នាំ ២០០៦ សម្រាប់ការបោះឆ្នោតថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខមានការិយាល័យបោះឆ្នោតកើតឡើងរហូតដល់ ១៦៩ការិយាល័យ ប្រជាពលរដ្ឋសរុបចំនួន ១៤៧៥២២នាក់ អាយុ ១៨ឆ្នាំឡើង ៧៨២៨៥នាក់ ក្នុងនោះស្ត្រី ៣៨០៣១នាក់ អ្នកដែលមានឈ្មោះទៅបោះឆ្នោតនៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០៧ ។ បញ្ជីបោះឆ្នោតឆ្នាំ ២០០៥ មានចំនួន ៦៨៤៧៧នាក់ ចុះឈ្មោះថ្មី ១៧៥៤២នាក់ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំនួន ១៥៧០នាក់ ដូច្នេះឈ្មោះក្នុងបញ្ជីបោះ ឆ្នោតក្នុងឆ្នាំ២០០៦សរុប ៨៤៤៥០នាក់ គិតជាភាគរយស្មើនឹង ១០៧.៨៧% សួរថា តើហេតុអ្វីបានជាបញ្ជីស្ថិតិលើសផែនការដល់ ៧.៨៧% ទៅនេះ គឺអាស្រ័យដោយស្ថិតិក្រុមប្រឹក្សាឃុំ ស្មៀនឃុំដែលបានធ្វើឡើងមកពុំអាចគ្រប់គ្រាន់អាស្រ័យដោយការអភិវឌ្ឍន៍ និងរីកចំរើននៃខេត្តឧត្តមានជ័យ ប្រជាពលរដ្ឋចេះតែហូរចូលមកពី ទី១ បណ្តាក្រុមហ៊ុនក្នុងស្រុកមួយចំនួននៅក្នុងអន្លង់វែង និង ស្រុកត្រពាំងប្រាសាទការវិនិយោគដាំដំណាំកសិផល ទី២ ការបើកច្រកចេញចូលទាំងពីររបស់ខេត្តឧត្តមានជ័យ និងទី៣ ការ វិវឌ្ឍន៍ស្រុក២ ដែលសំខាន់ គឺស្រុកអន្លង់វែង និងត្រពាំងប្រាសាទ ។ ម្យ៉ាងវិញទៀតការងារចុះឈ្មោះ គឺយើងគិតរហូតដល់ពេលបោះឆ្នោត ដែលការបោះឆ្នោតប្រព្រឹត្តឡើងនៅក្នុងថ្ងៃទី ១ ខែ មេសា ដូច្នេះយើងគិតលើស ៤ខែ ។ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំមានរយៈ២០ថ្ងៃ គឺចាប់ពីថ្ងៃទី ១ រហូតដលថ្ងៃទី ២០ ខែ តុលា ក្នុងឆ្នាំ ២០០៥ ដែលមានការស្នើសុំខាងផ្នែកចុះឈ្មោះពីក្រុបព្រឹក្សាឃុំ ។ គ.ជ.ប បានសម្រេចបន្ថែមចំនួន ២ថ្ងៃ ទៀតចំពោះភូមិមួយចំនួនទៀតដែលនៅសល់ប្រជាពលរដ្ឋច្រើនមិនទាន់បានចុះឈ្មោះ ក្នុងឆ្នាំ ២០០៦ កន្លងមកថ្មីៗនេះ គ.ជ.ប បានសម្រេចបន្ថែមថ្ងៃពេល ៤ថ្ងៃ ទៀតសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅទូទាំងប្រទេស ។ ផលលំបាក មានភូមិមួយចំនួននៅឆ្ងាយដាច់ស្រយាលពីឃុំចង្ងាយប្រមាណ ២០ ទៅ ៣០គីឡូម៉ែត្រ មានភូមិសាស្រ្តស្មុគស្មាញត្រូវប្រើប្រាស់ មធ្យោបាយថ្មើជើង ផ្លូវទឹក ដោយទូកជាដើម ជាក់ស្តែងនៅឃុំកោះស្បូវ ភូមិកូនគ្រាល ស្រុកសំរោង ឃុំទេល ស្រុកបន្ទាលអំពិល ឃុំពង្រល់ និងឃុំចង្រោង ស្រុកចង្រោង ស្រុកមួយចំនួនខាងលើនៅសល់ប្រជាជនប្រមាណ ១៥ ទៅ ៣០នាក់ ក្នុង ១ភូមិៗ ដែលពុំបានចុះឈ្មោះបោះឆ្នោត ម្យ៉ាងទៀតស្មៀនឃុំមិនមានពេលគ្រប់គ្រាន់សម្រាប់ទៅចុះឈ្មោះ ។ ការកែតម្រូវទិន្នន័យ និងឈ្មោះមានបរិមាណច្រើន ពីព្រោះប្រជាពលរដ្ឋភាគច្រើនបានធ្វើអត្តញ្ញាណប័ណ្ណសញ្ជាតិខ្មែរប៉ុន្តែខុសអក្ខរាវិរុទ្ធទិន្នន័យពីបញ្ជីបោះឆ្នោត ប្រជាជនមួយចំនួនធ្វើអត្តញ្ញាណប័ណ្ណក្រោយបញ្ជីបោះឆ្នោតដូច លោក **ឱក សេរី សោភក្តិ** បានថ្លែងរួចមកហើយពីបញ្ហាឈ្មោះ គឺមានខុសច្រើនហើយនៅក្នុងខេត្តឧត្តមានជ័យ មានខុសរហូតទៅដល់ ៤៥% រហូតទៅដល់ខុសថ្ងៃ ខែ ឆ្នាំកំណើត ប៉ុន្តែយោងទៅតាមសេចក្តីណែនាំមួយរបស់ គ.ជ.ប ថា ឈ្មោះដែលមានសូរស័ព្ទស្រដៀងគ្នាអាចយកជាផ្លូវការបាន បើសិនជាយើងកែទាំងអស់ស្រុកទាំងអស់ គឺមិនមានក្រដាស់គ្រប់គ្រាន់ ។ ករណីទាំងអស់នេះទាំងភាពងាយស្រួល ភាពលំបាក ឬ បញ្ហាដំណោះស្រាយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតសុទ្ធតែបានអញ្ជើញគ្រប់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងកងកំលាំងសន្តិសុខឱ្យបានចូលប្រជុំ ហើយបានឯកភាពគ្នារួចអស់ហើយ ។ ប្រជាពលរដ្ឋមួយចំនួនទៀតគ្មានអត្តញ្ញាណប័ណ្ណ ឬបាត់អត្តញ្ញាណប័ណ្ណ ប្រជាពលរដ្ឋទាំងនោះត្រូវយករូបថត ២សន្លឹក និង

សាក្សី ២រូប ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឃុំទៅជួបឃុំដើម្បីធ្វើលិខិតបញ្ជាក់អត្តសញ្ញាណទម្រង់ ១០១៨ ។ ប្រជាពលរដ្ឋមួយចំនួនខ្វះរូបថតបិទលើទម្រង់ ១០១៨ ស្មៀនឃុំឱ្យប្រជាពលរដ្ឋរូបនោះជំពាក់រូបថត ។ អនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.ប ។ បើសិនជាមិនមានទម្រង់ ១០១៨ នោះទេ គឺប្រជាពលរដ្ឋគ្មានសិទ្ធិទៅបោះឆ្នោតនោះទេដូចនេះ ហើយអាជ្ញាធរខេត្តរៀបចំការបោះឆ្នោត ខេត្តឧត្តរមានជ័យ បានធ្វើលិខិតក្រើនរំលឹកមួយហើយដល់ក្រុមអាជ្ញាធរស្តីអំពីបញ្ហាទម្រង់ ១០១៨ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋដឹងឱ្យមានសិទ្ធបោះឆ្នោតគ្រប់ៗគ្នា ។ ការផ្តល់ទម្រង់ ១០១៨ មានចំនួនមិនគ្រប់គ្រាន់ដោយ គ.ជ.ប មិននឹក ស្មានថា ប្រជាពលរដ្ឋយើងខ្វះទម្រង់ ១០១៨ យ៉ាងច្រើន ។ បញ្ហាផ្សេងៗទាក់ទងនឹងចំនុចមួយខាងលើគណបក្សនយោបាយ និងអាជ្ញាធរមូលដ្ឋាន បានស្នើសុំឱ្យស្មៀនទៅចុះឈ្មោះទៅភូមិមួយចំនួនដែលមានឧត្តមសិក្សារដើម្បីធ្វើការចុះឈ្មោះប្រជាពលរដ្ឋដែលនៅ សល់ ។ លោក ក៏បានមានប្រសាសន៍ទៀតថា ឆ្លើយតមនឹងបញ្ហាខ្វះខាតនិងផលពិបាកខាងលើលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក៏បានសម្រួល និងដោះស្រាយដូចតទៅ: ១. ពាក់ព័ន្ធនឹងភូមិដែលនៅឆ្ងាយស្មៀនភូមិមិនមានពេលគ្រប់គ្រាន់ គ្មានមធ្យោបាយ និង ភ្មានលទ្ធភាពចុះទៅតាមឃុំបាន លេខាធិការដ្ឋានរៀបចំការបោះឆ្នោតបានសុំកិច្ចសហការពីក្រុមអាជ្ញាធរមូលដ្ឋានគ្រប់ដំណាងគណបក្សនយោបាយរិះរកគ្រប់មធ្យោបាយដើម្បីដឹកជញ្ជូនប្រជាជនទាំងនោះមកប្រមូលផ្តុំគ្នានៅភូមិសាស្រ្តធំដើម្បីឱ្យស្មៀនឃុំចុះឈ្មោះជូន វិធានការខាងលើបានទទួលលទ្ធផលជាផ្លែផ្កា ដោយប្រជាជនមួយចំនួនធំបានមកចុះឈ្មោះបោះឆ្នោត ។ ២. បញ្ហាប្រជាជនខ្វះរូបថត លេខាធិការដ្ឋានរៀបចំការបោះឆ្នោតបានអញ្ជើញគ្រប់គណបក្សនយោបាយ ដើម្បីសហការ និងដោះស្រាយតាមលទ្ធភាព លទ្ធផលទទួលបានគណបក្សមួយចំនួនដូចជាគណកប្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុន ស៊ិនប៉ិច បានបញ្ជូនដំណាងរបស់ខ្លួនដើម្បីចុះជួយថតរូប ដល់ប្រជាពលរដ្ឋ ។ គណបក្សប្រជាជនកម្ពុជាបានឧបត្ថម្ភ ១០១៨ ចំនួន ៥០០០សន្លឹក គណបក្ស សម រង្ស៊ី បានផ្តល់ ១០០០សន្លឹក គណបក្ស ហ្វុន ស៊ិនប៉ិច បានឧបត្ថម្ភចំនួន ៥០០០សន្លឹក អង្គការខមហ្វ្រែលបានជួយ ២៥០០សន្លឹក ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៍ថា មុនពេលសម្រាក លោក បានចោទសួរទៅខាងក្រុមព្រឹក្សាស្រុកសំរោងអំពីព័ត៌មានដែល លោក ទទួលបានដែលថាប្រជាពលរដ្ឋរបស់យើងនៅ ៣ភូមិ មិនទាន់បានឱ្យចុះឈ្មោះបោះឆ្នោតបានត្រឹមត្រូវ និងគ្រប់គ្នាទេ គឺនៅភូមិបាក់នឹម កូនដំរី និងអូរកន្សែង ។

លោក **ផាត់ វ៉ិត** ជំទប់ទី១ ឃុំសំរោង ភូមិកូនដំរី បានមានប្រសាសន៍បញ្ជាក់ក្នុងបញ្ហានោះថា ពិតជាមានកើតមានឡើងខ្លះៗមែន ឧទាហរណ៍ដូចជានៅ ភូមិអូកន្សែងឃុំមានការចុះឈ្មោះនៅក្នុងភូមិ គឺចុះឈ្មោះបានមួយថ្ងៃពេញ ប៉ុន្តែ ប្រជាពលរដ្ឋមិនបាននៅក្នុងភូមិ ដោយសារពួកគាត់ជាប់ទៅធ្វើចំការ ឬ ទៅឆ្ងាយពីភូមិ ក្រោយពីចុះឈ្មោះក្នុងភូមិរួចការចុះឈ្មោះបានធ្វើឡើងនៅក្នុង ឃុំ ៣ថ្ងៃទៀត រហូតដល់ហួសថ្ងៃចុះឈ្មោះហើយពួកគាត់នៅតែមិនទាន់មកទៀតនេះជាបញ្ហាដែលប៉ះពាល់ដល់ការចុះឈ្មោះបោះឆ្នោតរបស់គាត់ ។ លោកបានបន្ថែមទៀតថា ពេលដែល លោក ចុះទៅនោះក៏មានទាំងការប្រកាសតាមមេក្រូដើម្បីឱ្យប្រជាពលរដ្ឋ ឱ្យបានដឹងពីព័តិមានការចុះឈ្មោះបោះឆ្នោតនេះ ប៉ុន្តែដោយឡែកគាត់មិនបាននៅទីនោះ នេះជាបញ្ហាមួយ ។ ឯបញ្ហាមួយទៀត គឺនៅភូមិកូនដំរី គឺជាក់ស្តែងដោយសារយើងមិនអាចក្តាប់បានអ្នកចំណូលថ្មីនៅក្នុងភូមិដោយអ្នកចំណូលថ្មីទាំងនោះគ្មានក្នុងក្របខ័ណ្ឌភូមិ និងមិនបានប្រាប់អាជ្ញាធរ បញ្ហានេះហើយធ្វើឱ្យពួកយើងពិបាកក្នុងការស្រាវជ្រាវ និងមិនបានចុះទៅដល់ ។ លោក បានមាន ប្រសាសន៍ថា ដោយឡែកនៅភូមិបាក់នឹម មិនត្រឹមតែទៅទៃថែមទាំងស្នាក់នៅទីនោះទៀតដើម្បីប្រមូលប្រជាពលរដ្ឋឱ្យមកចុះឈ្មោះបោះឆ្នោត ប៉ុន្តែក្នុងនោះប្រជាពលរដ្ឋមួយចំនួនមានការរេរាមកមិនកើតដោយសារពួកគាត់មានទីលំនៅមិនច្បាស់លាស់ ប្រជាពលរដ្ឋ មួយចំនួនទៀត ឧទាហរណ៍ គាត់មកក្រឡាញ់ដោយពួកគាត់មិនដឹងជាចុះឈ្មោះនៅឯណាពួកគាត់ក៏មកដោយមិនមានលិខិតបញ្ជាក់ពី មេឃុំ

ដែលនៅក្នុងនោះ ក៏បានសម្របសម្រួលចុះបានមួយចំនួនដែរដូចជានៅភូមិរនាបបានប្រហែល ៤៥% ដែរ នេះបើតាម លោក ពិនិត្យមើល ។ លោក បានមានប្រសាសន៍ដែរថា នៅក្នុងឃុំសំរោងការចុះឈ្មោះបោះឆ្នោតមានច្រើនជាងឆ្នាំមុនៗ បើតាមរយៈការចុះឈ្មោះដែលបានធ្វើឡើងប៉ុន្មានថ្ងៃមុន នឹងឈប់នេះដោយសារតែមួយចំនួនដែលមេឃុំទទួលស្គាល់ដោយអ្នកដែលមិនបានមក យើងអាចទំនាក់ទំនងទៅបងប្អូនរបស់ពួកគេអោយចុះឈ្មោះឱ្យបានមួយចំនួនដែរ ។ ដូច្នេះដូចអ្វីដែល លោក ជំរាបជូនខាងលើបញ្ហាខ្វះខាតខ្លះៗ ដូចជានៅក្នុងភូមិបាក់នឹម ភូមិអូកន្សែង ហើយខ្វះខាតជាងគេ គឺភូមិកូនដំរី គឺមិនបានចុះពិតប្រាកដដោយសារមិនច្បាស់លាស់ហើយការធ្វើ ដំណើរក៏ឆ្ងាយដែរ ។

លោក **ឱក សេរី សោភក្តិ** បានមានប្រសាសន៍អោយស្នើសុំឱ្យ លោក ប្រធានលេខាធិការកត់បញ្ហាទាំងអស់ ដើម្បី លោក ជំរាបសួរទៅវាលគ្និនចំនួន ៥នាក់ឆ្លើយម្តង ហើយ លោក ក៏បានមានប្រសាសន៍ថា លោក សូមប្រគល់ប្រសាសន៍នេះទៅ លោក ។ លើសពីនេះទៅទៀត ដែល លោក ៣ ប្រសាសន៍ លោក ជំទប់ទី១ បានលើកឡើង លោក មានការសោកស្តាយចំពោះប្រជាពលរដ្ឋយើង ។ ការបោះឆ្នោតនៅប្រទេសកម្ពុជាយើងធ្វើឡើងដោយមិនមានការបង្ខិតបង្ខំ គឺធ្វើឡើងតាមតែប្រជាពលរដ្ឋយើងចង់ មិនដូចប្រទេសមួយចំនួនដែលមានការបង្ខំឱ្យត្រូវតែចុះឈ្មោះបណ្តោះទេ ប៉ុន្តែ លោក នៅតែមានការសាកស្តាយព្រោះថា គាត់ជាប្រជាពលរដ្ឋខ្មែរម្នាក់ ទោះបីជាគាត់ផ្លាស់ទីលំនៅនៅទីណាក៏យើងត្រូវតាមចុះឈ្មោះគាត់ឱ្យបានដែរ ។ លោក បានបន្តសន្យាថា នឹងយកបញ្ហានេះទៅលើកឡើងនៅថ្នាក់ជាតិជាមួយ នឹងក្រសួងមហាផ្ទៃដើម្បីធ្វើការនេះ ជាពិសេសភូមិកូនដំរី ។

លោក **លឿន តឹក** ជំទប់ទី២ ឃុំបេង បានមានប្រសាសន៍ថា នៅភូមិរបស់ លោក ឃើញថា ការចុះឈ្មោះបោះឆ្នោតមិនសូវបានគ្រប់គ្នានៅឡើយទេ ដោយសារទំរង់ ១០១៨ ស្មៀនឃុំគិតថា នៅមានការខ្វះខាតដូចនេះ លោក ស្នើសុំអោយចុះឈ្មោះអ្នកដែលមានអាយុទើបតែគ្រប់ ១៨ឆ្នាំ ។ ដោយឡែកប្រជាពលរដ្ឋចុះមកហើយយើងមិនបានចុះឈ្មោះឱ្យគេដោយសារយើងខ្វះទំរង ១០១៨ ដូចនេះ ស្មៀនឃុំសូមឱ្យចុះឈ្មោះតែអ្នកថ្មីទៅ អ្នកចាស់ចាំចុះឈ្មោះក្រោយទៅប៉ុន្តែរហូតមកដល់ពេលនេះគាត់មិនទាន់បានចុះឈ្មោះបន្តទៀតទេ ។

លោក **ដាត់ វ៉ិត** ជំទប់ទី១ ឃុំសំរោង ភូមិកូនដំរី សូមមានប្រសាសន៍បន្ថែមទៀតទាក់ទង នឹងការធ្វើអត្តសញ្ញាណប័ណ្ណថា នៅឃុំរបស់លោក គឺឃុំសំរោងការធ្វើអត្តសញ្ញាណប័ណ្ណ គឺបានចប់ហើយប៉ុន្តែមិនបានលទ្ធផលដោយសារមិនបានមកដល់ប្រជាពលរដ្ឋហើយនៅសល់រយៈពេលតែមួយខែទៀតទេ ដែលប្រជាពលរដ្ឋត្រូវចុះឈ្មោះបោះឆ្នោត ដូចនេះបើ លោក ប៉ូលិសធ្វើមិនទាន់វាជាបញ្ហាមួយយើងគួរចាប់អារម្មណ៍ដែរ ហើយលេខគាត់បានគ្រប់គ្នាប៉ុន្តែមិនទាន់ចេញជាអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋនៅឡើយ នេះជាបញ្ហាមួយនៅក្នុងភូមិរបស់ លោក ។

លោក **សំ វីរៈ** អនុប្រធានអចិន្ត្រៃ គណបក្ស ហ៊្វុនស៊ិនប៉ិច បានមានចំណាប់អារម្មណ៍ទៅ និងបញ្ហាការឃោសនាបោះឆ្នោត លោក សូមសំនូមពរឱ្យគ្រប់គណបក្សនយោបាយទាំងអស់ បំបាត់អោយអស់នូវអំពើរហឹង្សា ការបំផិតបំភ័យ ការបន្លាច និងការញុះញង់ប្រជាពលរដ្ឋ ។ ការឃោសនាដោយដាក់ថា អ្នកនេះអាក្រក់ អ្នកនោះអាក្រក់ ដូចសម្តេចហ៊ុន សែន លោក បានមានប្រសាសន៍ថា កុំឃោសនាតាមបែបពាណិជ្ជកម្ម បើយើងចង់បំបាត់បញ្ហាទាំងនេះបានយើងអាចឈានទៅរកការបោះឆ្នោតប្រកបដោយភាពរលូន ដូចឯកឧត្តម បានមានប្រសាសន៍ហើយការបោះឆ្នោតមានឈ្នះ មានចាញ់ អ្នកឈ្នះត្រូវឈ្នះដោយយុត្តិធម៌ ហើយអ្នកចាញ់ដោយសុខចិត្តទទួលយកលទ្ធផល ម្យ៉ាងទៀតការបោះឆ្នោត បើតាម លោក គិតការបោះឆ្នោតឆ្នាំនេះប្រហែលជាយឺតយ៉ាវបន្តិច ព្រោះនៅមានបញ្ហា

ច្រើនមិនទាន់ធ្វើ ដូចជាអត្តសញ្ញាណប័ណ្ណធ្វើមិនទាន់បាន ឯកសារមិនគ្រប់គ្រាន់ ការចុះឈ្មោះបោះឆ្នោត ចុះមិនបាន លោក សូមអោយបងប្អូនប្រជាពលរដ្ឋទាំងអស់ចុះទំរង់ ១០១៨ ទៅទើបរហ័ស ។

លោក **ជិញ សំភួ** បានមានប្រសាសន៏ឆ្លើយតបទៅ និងសំណួររបស់វាគ្មិនថា បញ្ហានៅភូមិ បាក់នឹម និង ភូមិកូនដំរីដែលខាងឃុំសំរោងបានលើកឡើង គឺថា នាពេលនោះជារដូវវស្សា លោក ចាំបានថា នៅក្នុងថ្ងៃមួយនោះ គឺស្មៀនឃុំរួមសហការទាំងអាជ្ញាធរមូលដ្ឋាន និងកងកំលាំងប៉ូលិសសុខចិត្តដើរទៅទីនោះ ហើយស្នាក់នៅទីនោះ ១យប់ ដើម្បីចុះឈ្មោះបោះឆ្នោត សួរថាមូលហេតុអ្វីបានជាចុះឈ្មោះមិនបានអស់ ពេលដែលយើងឡើងប្រកាសផ្សាយ ហើយនិងអោយមេភូមិរៀបចំការចុះឈ្មោះនៅថ្ងៃដែលគាត់ចុះទៅនៅពេលដែលចុះរយៈពេល ១ថ្ងៃ នោះ គឺប្រជាពលរដ្ឋមួយចំនួនជាប់ទៅធ្វើស្រែចំការ លោក ទទួលស្គាល់ថា ចុះមិនបានអស់ទេ បើតាម ស្ថិតិ ៦៥% មកប្រៀបធៀប នឹងស្ថិតិមួយៗ ចំណែកភូមិកូនដំរី លោក ទើបតែបាននៅថ្ងៃនេះថា មិនបានចុះឈ្មោះ ឬ មួយភូមិកូនដំរីប្រជាពលរដ្ឋទើបតែមករស់នៅ ជួនកាលគាត់មានឈ្មោះហើយកាលពីឆ្នាំមុន ដូចនេះត្រូវធ្វើការស្រាវជ្រាវថា គាត់ផ្លាស់មកពីទីណា ពីព្រោះភូមិនេះទើបតែកើតឡើងនៅឆ្នាំនេះ ចុងឆ្នាំហើយមើលទៅគិតទៅដល់ ពេលចុះឈ្មោះបោះឆ្នោតហើយដែលចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី ១ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦ ហើយក្នុងនោះស្មៀនឃុំក៏បានឯកភាពផងដែរ ។ បញ្ហាមួយទៀតគឺបញ្ហាស្តីពីឃុំបេងជំទប់ទី២ បានលើកឡើងពីបញ្ហា ១០១៨ លោក បានមានប្រសាសន៏ថា លោក បានលើករួចហើយ គ.ជ.ប បានផ្តល់យ៉ាងច្រើនរហូតដល់យើងសុំគ្រប់គណបក្ស ហើយក៏បានរាយការណ៏ រួចហើយគណបក្សណាជូនប៉ុន្មាន ហើយក្នុងនោះក៏មានសេចក្តីជូនដំណឹងមួយទៀតរបស់ គ.ជ.ប ស្តីអំពីបញ្ហាដោយសារខ្វះទំរង់ ១០១៨ យ៉ាងច្រើនមកហើយ អ្នកដែលជាប់ឈ្មោះ និងកំពុងតែជាប់ឈ្មោះ គឺចាប់ផ្តើមផ្តល់ជូនក៏ប៉ុន្តែអ្នកដែលមានឈ្មោះហើយទុកសិនចាំក្រោយ ហើយរហូតដល់ថ្ងៃ នេះលោកជឿថាគាត់រកបានហើយទំរង់ ១០១៨ មាននៅក្នុងក្រុមប្រឹក្សាឃុំទាំងអស់ គឺនៅស្មៀនឃុំដូច្នេះយ៉ាងណាតែធ្វើទំនាក់ទំនងជាមួយស្មៀនភូមិហើយ លោក បានដឹងថា ដូច លោក បានរាយការណ៏ជូនហើយ លោក មិនលាក់លៀមទេដើម្បីតម្លាភាព និងមានលក្ខណៈត្រង់ទៅត្រង់មក គឺគ្រប់គណបក្សនយោបាយ ដូច លោក បានជំរាបរួចមកហើយ គឺគាត់បានទៅជួយថតដល់ប្រជាពលរដ្ឋ ហើយខែនេះ លោកដឹងទៀតថា គណបក្សនយោបាយមួយចំនួនរូបថតបានហើយដែលរូបថត ថតទាំងពីខែ៩ ហើយ លោក ជឿជាក់ថា ថ្ងៃនេះបានចែកខ្លះហើយ ដូចនេះហើយគួរតែគ្រប់អាជ្ញាធរមូលដ្ឋានជួយជំរុញយ៉ាងណាឱ្យប្រជាពលរដ្ឋមានរូបថត ដូចនេះហើយគ្រប់ក្រុមប្រឹក្សាឃុំទាំងអស់នៅក្នុងស្រុកយើងលើកលែងតែនៅក្នុងស្រុកអន្លង់វែង និងត្រពាំងប្រាសាទ ទៅចុះដែលនៅខ្វះខាតមិនទាន់មានគ្រប់គណកបក្សនយោបាយ បើយើងនិយាយរួម គឺនៅក្នុងប៉ុន្មានស្រុកមានបីស្រុកដែលក្រុមប្រឹក្សាភូមិមានស្ទើតែគ្រប់គណបក្សទាំងអស់ គឺជួយធ្វើយ៉ាងម៉េចជំរុញ និងសហការដើម្បីឱ្យគាត់បានទៅបោះឆ្នោត បើសិនជារូបថតមានត្រឹមត្រូវហើយលោកទទួលស្គាល់ គេមិនឱ្យផ្តិតថ្មីទេ ប៉ុន្តែថ្ងៃនេះមានហើយ គឺរៀបចំបញ្ចេញឱ្យគាត់នូវទំរង ១០១៨ ដើម្បីឱ្យគាត់មានសិទ្ធិបោះឆ្នោត គឺយើងការពារប្រយ័ត្នដល់ថ្ងៃបោះឆ្នោត គាត់មិនមានអ្វីទាំងអស់ ដូច្នេះយើងបានដឹងរួចហើយថា មានច្បាប់លើកឡើងថា ក្រុមប្រឹក្សាឃុំសូម្បីតែមិនបញ្ជាក់អំពីបញ្ហាចេញទំរង់ ១០១៨ ជូនប្រជាពលរដ្ឋទេនោះ នឹងមានទោសសេចក្តីណែនាំមានហើយ ហើយបានដាក់ជូនក្រុមព្រឹក្សាឃុំទាំងអស់ហើយខាងឃុំសំរោងបានមានប្រសាសន៏ហើយ ស្តីពីការធ្វើអត្តសញ្ញាណប័ណ្ណដែលពុំទាន់បានទទួលនោះ ដែលបងខាងវាគ្មិនបានមានប្រសាសន៏អោយគេធ្វើទំរង់ ១០១៨ គឺដឹងតែបានទៅបោះឆ្នោត លោក សូមអរគុណដល់សមាជិកក្នុងអង្គប្រជុំហើយបើមានបញ្ហាអ្វីសូមសួរឡើងវិញ ។ ឆ្លៀតក្នុងឱកាសនេះ លោក ក៏បានមានជំរាបបន្ថែមទៀតថា នៅថ្ងៃទី៨ ទៅ គឺទទួលបានប័ណ្ណព័ត៌មានហើយចាប់ពីថ្ងៃទី៨ ទៅ គឺគ្រប់អាជ្ញាធរទាំងអស់ដែលបានចូលរួមនៅទីនេះទទួលយកព័តិមានទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ព្រោះ

គ.ជ.ប បានបង្រៀនគ្រប់គណបក្សនយោបាយ អាជ្ញាធរដែនដីរួចហើយ ជាពិសេសឃុំស្តីពីបញ្ហាចែកព័តិមាន ដូច្នេះថ្ងៃទី៨ ខែកុម្ភៈ គេចាប់អនុវត្តន៏ចែក រហូតដល់ថ្ងៃទី ៨ ខែ មិនា ទើបចប់ នៅពេលដែលចែកចប់ក្រដាស់ព័តិមានទាំងនោះ នឹងត្រូវបញ្ជូនទៅគណកម្មាធិការឃុំរៀបចំការបោះឆ្នោត ហើយប្រជាជនអាចទៅយកបានទៀត ដូច្នេះបើមិនជំរុញឱ្យប្រជាពលរដ្ឋទៅយកប័ណ្ណព័តិមាន និង ទំរង់ ១០១៨ ទេ វានឹងមានការពិបាកនៅថ្ងៃដែលទៅរកការិយាល័យរកលេខឈ្មោះរបស់ខ្លួន និង ទីតាំងរបស់ខ្លួន ។ លោក ក៏បានរំលឹកថា ទោះបីជាមានប័ណ្ណព័តិមានពីមុនហើយក៏ដោយក៏ត្រូវតែទៅយកម្តងទៀតដែរ ។ គ.ជ.ប បានលើកឡើងថា មានគណបក្សមួយចំនួនគាត់បានប្តឹងថា សកម្មជនរបស់គណបក្សនយោបាយរបស់គាត់ទៅបោះឆ្នោតមិនទាន់ពេល ទៅរកការិយាល័យមិនឃើញរកការិយាល័យឃើញហើយរកឈ្មោះមិនឃើញទៀតបណ្តាលអោយហួសពេលហួសម៉ោង ដូចនេះថ្ងៃនេះ លោក បានចែកប័ណ្ណព័តិ មាន ហើយ គឺដឹងតែរកឃើញដែលក្នុងនោះមានប្រាប់ទីតាំងការិយាល័យ លេខរៀងប៉ុន្មានត្រូវទៅការិយាល័យណា កន្លងមកអស់ លោក បានដឹងហើយថា មានតែ ៥ផ្លូវ ម្លោះហើយមានយើងមានតែ ៥នាក់ ថ្ងៃនេះក្រុមប្រឹក្សាភូមិនៅអណេន្តទី ២ មាន ៦នាក់ បន្ថែម ម្នាក់នោះដើម្បីជួយជាអ្នកស្តាប់ព័តិមានពេលបោះឆ្នោត ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៏ថា រឿងចែកប័ណ្ណព័តិមានជារឿងលើកទី ២ ដូចដែលយើងបានដឹងហើយកាលពីខែ វិច្ឆិកា ឆ្នាំទៅ គ.ជ.ប បានចែកប័ណ្ណព័តិមានលើកទី ១ ហើយយើងបានរៀនសូត្រច្រើនណាស់អំពីឥរិយាបទ និងអាកប្បកិរិយារបស់មេភូមិដែល លោក ទទួលភារកិច្ចយកទៅចែកឱ្យប្រជាពលរដ្ឋ ហើយ ខប់សែល បានជជែកវែក ញែកគ្នាបីខែជាប់ៗគ្នាពីរឿងដែល លោក បានលើកឡើង ។ បានជាយើងធ្វើការជាមួយ UNDP ចេញនូវសៀវភៅណែនាំដើម្បីធ្វើដូចម្តេចដើម្បីអោយមានតម្លាភាព និងអព្យាក្រឹតភាពសំរាប់ការចែកប័ណ្ណលើកទី ២ សំរាប់មេភូមិចាប់ពីថ្ងៃទី ៨ ខែ កុម្ភៈ រហូតដល់ថ្ងៃ ៨ ខែ មិនា ហើយលើកនេះសូមឱ្យគណបក្សនយោបាយ សង្គមស៊ីវិល មេត្តាជួយតាមដានទាំងអស់គ្នាថា តើការចែកព័តិមានទី២ នេះ មានតម្លាភាពបានទៅដល់ប្រជាពលរដ្ឋគ្រប់គ្នាដែរ ឬ អត់ បើគាត់មិននៅត្រូវធ្វើចំណាក់ស្រុកទៅឆ្ងាយមិនទទួលបាននោះមិនជាបញ្ហាទេប៉ុន្តែបើគាត់នៅតែមិនបានទេនោះទើបជាបញ្ហាដែលយើងធ្វើការមិនបានជិតដល់ ហើយដោយសារកៀកដល់ថ្ងៃបោះឆ្នោតតែកាលណាមានបញ្ហាម្តងទៀត បញ្ហានោះអាចក្លាយជានយោបាយពេលនោះយើងពិបាកហើយ ដូច្នេះចាប់ពីស្អែកទៅកិច្ចការសំខាន់របស់មេភូមិ មេឃុំ គឺធ្វើយ៉ាងណាប័ណ្ណព័តិមាន ឱ្យដល់ដៃប្រជាពលរដ្ឋដែល លោក បានចុះឈ្មោះរួចហើយ ហើយប័ណ្ណព័តិមាន ជាប័ណ្ណបញ្ជាក់ជាផ្លូវការថា លោក បានចុះឈ្មោះរួចហើយការិយាល័យបោះឆ្នោតនៅកន្លែងនេះ អោយទៅបោះឆ្នោតនៅថ្ងៃទី ១ ខាងមុខនេះកន្លែងនេះ ។

លោកស្រី **អ៊ឹម ចែម** មេឃុំត្រពាំងតាវ គណបក្ស ប្រជាជន បានលើកឡើង ៤ចំនុចៈ **ទី១** កាប៉ះពាល់ដល់ការដាក់ផ្លាកគណបក្ស ដែលប្រជាពលរដ្ឋបានទៅសួរក្រុមអ្នកដាក់ផ្លាកគណបក្សថា តើបានទៅសួរប្រធានភូមិហើយ ឬ នៅមុនពេលដាក់ផ្លាកគណបក្សនេះ? ពួកគេតបមកវិញដោយសម្តីមិនសមរម្យថា ពួកគាត់មិនទៅសួរទេនាំតែថោក នេះជាបញ្ហាមួយដែលកើតឡើងនៅឆ្នាំ ២០០១ និង ២០០២ ដែលធ្វើឱ្យមានការប្តឹងប្តល់គ្នា ហើយក៏បានដោះស្រាយរួចហើយដែរ ។ **ទី២** ការបោះឆ្នោតនៅអាណត្តទី១ មានបញ្ហាប៉ះពាល់ដល់ការទំលាក់ផ្លាកគណបក្ស សមរង្ស៊ី ក្នុងឃុំរបស់លោកស្រី ។ នេះមិនមែនជាគោលបំណងរបស់លោកស្រីទេ គឺប្រជាពលរដ្ឋជាអ្នកផ្ទាល់គ្នាដាក់លុយ រវាងគណបក្សប្រជាជន និងគណបក្ស សមរង្ស៊ី ហើយពួកគេបានភ្នាល់ផថា បើខាងគណបក្សប្រជាជនចាញ់ ត្រូវបង់លុយ ៥០០០០រៀល បើគណបក្ស ប្រជាជន ឈ្នះពួកគេ នឹងអោយប្រជាជនទៅទំលាក់ផ្លាកគណបក្ស សមរង្ស៊ី ករណីនេះកើតឡើងនៅឃុំរបស់លោកស្រីចំនួន ២លើក ។ ចំពោះ លោកស្រី ទទួលតួនាទីជាមេភូមិ មេឃុំ ដែលមានតួនាទីអប់រំប្រជាជន និងធ្វើការសំរបសំរួល តាមសំណូមពររបស់ថ្នាក់ដឹកនាំខាងលើថា យើងគឺបញ្ចប់សង្គ្រាមនេះដែលត្រឹមត្រូវតាមបំណងរបស់ប្រជាពលរដ្ឋ

។ **ទី៣** នៅអាណត្តិទី ២នេះ ចំពោះក្រុមប្រឹក្សាឃុំរបស់លោកស្រីដែលមាន ៩នាក់ ៦នាក់ទាំងស្មៀន និងជំទប់ទី២ ខាងហ្វុនស៊ិនប៉ិច មិនមានខាង គណបក្ស សមរង្ស៊ី ទេ ហើយនៅក្នុងនេះទៀត គឺបានសហការណ៍ធ្វើការងាររដ្ឋបាលពេលដែលចុះឈ្មោះបោះឆ្នោតបាន យ៉ាងល្អ ។ លោកស្រី មានគោលដៅធ្វើការជាមួយប្រជាជន ហើយ លោកស្រី បានចែកគ្នាចុះឈ្មោះជូនប្រជាជនអស់ហើយនៅក្នុង ក្រុមប្រឹក្សាឃុំរបស់ លោកស្រី ពេលទៅភូមិណា គឺក្រុមការងារទាំងអស់ចុះទៅជាមួយគ្នា ឯខាងគណបក្សផ្សេងគាត់ទៅក៏បានមិនទៅ ក៏បាន គឺមិនមានបញ្ហាអ្វីទេ ។ លោកស្រី បានមានប្រសាសន៍ដែរថា ពេលដែលក្រុមការងាររបស់ លោកស្រី ទៅចុះឈ្មោះដំបូងឱ្យ ប្រជាពលរដ្ឋមកពិនិត្យ គាត់ពិនិត្យហើយអ្នកដែលគ្មានឈ្មោះនៅក្នុងការិយាល័យ បានមកចុះឈ្មោះយ៉ាងកុះករហូតដល់ស្មៀនភូមិ ចុះឈ្មោះស្ទើតែមិនទាន់ ភូមិមួយៗពេលដែលផ្តល់ដំណឹងទៅ គឺប្រជាពលរដ្ឋមកតែម្តង ពួកគាត់ចង់បោះឆ្នោតណាស់ តែឃុំរបស់ លោកស្រី ត្រូវចុះម្តងទៀតដោយសារមិនទាន់បានចែកទំរង់ ១០១៨ ដល់ប្រជាពលរដ្ឋបានគ្រប់គ្នា និង ការថតរូបពួកគាត់មិនទាន់បាន គ្រប់ ១០០% ឯអ្នកថត គឺចុះថតជាប់ ដូច្នេះត្រូវចំណាយពេលវេលា ចំណាយថវិការ រហូតដល់ចុះឈ្មោះអត្រានុគោលដ្ឋាន ពីព្រោះវា ទាក់ទង នឹងអ្នកដែលមកចុះឈ្មោះត្រូវយកអត្រានុគោលដ្ឋានមក អ្នកមួយផ្នែកបង្ខំចុះឈ្មោះអត្រានុគោលដ្ឋាន មួយផ្នែកចុះឈ្មោះ បោះឆ្នោត ។ លោកស្រី បានមានប្រសាសន៍ថា ឃុំរបស់ លោកស្រី មាន២០០០ហើយថតមិនទាន់គ្រប់ ប្រាក់ដែលចំណាយផ្តិតរូបថត អស់ចំនួន ២លានរៀល ហើយដោយមួយសន្លឹកមាន តំលៃ១៥០០រៀល ម្យ៉ាងវិញទៀតពេលដែលដើរធ្វើការ ក៏ត្រូវចំណាយប្រាក់ដែរ ហើយថ្នាក់លើបានប្រាប់ថា នឹងជួយ ប៉ុន្តែមិនទាន់ដឹងជួយបានប៉ុន្មាននៅឡើយទេ អញ្ចឹង លោកស្រី គិតថាការងារនេះត្រូវការប្រាក់ ឧបត្ថមច្រើន ។ ចំណែកខាងចុះអត្រានុគោលដ្ឋានមាន ប្រជាពលរដ្ឋមួយចំនួនគាត់និយាយថា មិនមានថវិកាឱ្យអ្នកសរសេរទេពួកគាត់ មិនបានទៅធ្វើទេ ហើយ លោកស្រី បានអោយប្រធានភូមិកត់ឈ្មោះមកទាំងអស់ ហើយក្រុមប្រឹក្សាភូមិបានចេញលុយជួលស្មៀន ដែលទៅប្រចាំការពីរ បីនាក់ ម្នាក់បាន ១០០០០រៀលក្នុង ១ថ្ងៃ ដូច្នេះហើយបានជាធ្វើហើយតាមផែនការ ។ ដោយឡែកដែល លោកស្រីមានចំងល់ចង់សួរថា ចំពោះអ្នកដែលចូលមកនៅថ្មីហើយគាត់មិនបានធ្វើអត្រានុគោលដ្ឋាន ពីស្រុកកំណើតរបស់គាត់ ហើយផ្លាស់មករស់នៅក្នុងភូមិរបស់ លោកស្រី គាត់មិនទាន់មានឈ្មោះទៅបោះឆ្នោត ហើយទំរង់១០១៨ ក៏មិនទាន់ចុះអោយគាត់ ហើយហួសពេលទៀត ប្រជាពលរដ្ឋតែងតែមកសួរ លោកស្រីថា ហេតុអ្វីមិនចុះឈ្មោះអោយពួកគាត់ទៅបោះឆ្នោត លោកស្រី មិនទាន់ បានចុះឈ្មោះអោយពួកគាត់ទេ លោកស្រីចង់សួរថា តើត្រូវធ្វើដូចម្តេច ដើម្បីលោកស្រីបានយកទៅអនុវត្តន៍ អ្នកដែលមកថ្មីក្នុងខែធ្នូ ខែមករា និងអ្នកខ្លះត្រលប់ទៅស្រុកវិញយកប័ណ្ណផ្លាស់ទីលំនៅ ពេលមកវិញធ្វើអោយយឺតពេល លោកស្រី ចង់សួរថា តើត្រូវចុះឈ្មោះ អោយពួកគាត់ ឬក៏ចាំពេលអណត្តក្រោយដើម្បីអោយប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតទាំងអស់គ្នា ហើយរឿង មួយទៀតនៅឃុំ របស់លោកស្រី មានបញ្ហាខ្វះអត្តសញ្ញាណប័ណ្ណច្រើនព្រោះប្រជាពលរដ្ឋនៅឃុំលោកស្រី បានអោយទៅប៉ូលិសដែល ដើរថតដើរធ្វើពីរ សារហើយនៅតែមិនទាន់បានទៀតតាំងពីអ្នកដំបូងមកដោយមិនដឹងជាហេតុអ្វី ហើយប្រជាពលរដ្ឋចេះតែមកសួរថា ហេតុអ្វីបានជាពួក គាត់ថតច្រើនដងហើយនៅតែមិនបានទទួលអត្តសញ្ញាណប័ណ្ណ ។

លោក **ជិញ សំភូ** បានមានប្រសាសន៍ឆ្លើយតម នឹងសំនួរលោកស្រី **អ៊ឹម ចែម** ថា ដូចដែលអស់លោកបានលើកមកខាង ដើមថា ការចុះលើសរហូតដល់ ៧% ក្នុងពីរស្រុក ។ លោកបានជំរាបថា ប្រជាពលរដ្ឋដែលផ្លាស់មកថ្មីមិនអាចចុះឈ្មោះអោយបានទេ ពីព្រោះការកំណត់របស់ច្បាប់ក៏ដូចជាកំណត់របស់ គ.ជ.ប គឺនៅថ្ងៃទី១ រហូតដល់ថ្ងៃទី ២០ ខែ តុលា គឺយើងចុះឈ្មោះប្រចាំឆ្នាំនិមួយៗ រយៈពេលតែ ២០ថ្ងៃទេ ដូច្នេះនៅថ្ងៃទី១ រហូតដល់ថ្ងៃទី ២០ ខែ តុលា នឹងមានការចុះឈ្មោះថ្មីម្តងទៀត ។

លោក **វីក ជរ** វិទ្យុអាស៊ីសេរី បានមានសំណូមពរអោយសមាជិកនៃអង្គប្រជុំទាំងមូលលើកមតិយោបល់ឡើងដើម្បីជាសំណូមពរជូនទៅរាជរដ្ឋាភិបាល ។

លោក **ឃុំ សុខុន** តំណាងឃុំសំរោង បានមានប្រសាសន៍ថា ដោយឆ្លងកាត់កាបោះឆ្នោតឆ្នាំ២០០៣ កន្លងមកមានរឿងអយុត្តិធម៌ខ្លះដែល លោក បានទៅអង្កេតការណ៍ មេឃុំមានសិទ្ធិបោះត្រាលើក្រដាសសអោយមនុស្សទៅបោះឆ្នោតបាន ពេលដែលមេឃុំឃើញឈ្មោះណាមិនទាន់មកបោះ មេឃុំបានអោយមនុស្សផ្សេងបោះត្រាអោយមកបោះមួយទៀត ពេលម្ចាស់ឈ្មោះមកបោះគាត់និយាយថា ហេតុអ្វីឈ្មោះគាត់មិនទាន់បោះផងហេតុអ្វីបានជាបោះហើយ? ករណីនេះ លោកក៏បានដាក់ពាក្យបណ្តឹងទៅប្រធាន PEC ហើយលោកអ្នកប្តឹងមិនបានទៅដោះស្រាយទេ គឺឱ្យអ្នកតំណាងលោកទៅជំនួស ។

លោក **ធឹង សំបាន** ជំទប់ទី១ ឃុំក្រសាំង បានមានប្រសាសន៍ថា លោក មានបញ្ហា ២ ទាក់ទង នឹងទំរង់ ១០១៨ ដោយសារក្រុមប្រឹក្សាមេឃុំ ដែលធ្វើទំរង់ ១០១៨ ធ្វើផងឃោសនាផងថា ប្រជាពលរដ្ឋណាដែលគាត់ធ្វើអោយ ត្រូវតែបោះឆ្នោតអោយគាត់ ហើការធ្វើទំរង់១០ ១៨ គាត់មានការរើសអើងគណបក្ស គាត់ឱ្យតែខាងគណបក្សគាត់ ដូចនេះ លោក សូមសួរថា រឿងនេះត្រឹមត្រូវ និងស្របតាមច្បាប់ដែរទេ ?

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៍ជំរាបដល់អង្គប្រជុំថា ក្នុងចំណោមខេត្តជាច្រើនដែល លោក ឆ្លងកាត់មានបញ្ហាមួយចំនួនជាបញ្ហាក្តៅការតតាំងរវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាចក៏ជាបញ្ហាក្តៅដែរតាំងពីឆ្នាំ ១៩៩៩ គឺយើងដកស្រង់បានច្រើន ប៉ុន្តែអ្វីដែលយើងពេញចិត្តដែលមានភាពខុសប្លែកពីជំនាន់មុននោះ គឺទាំងគណបក្សប្រឆាំងទាំងគណបក្សកាន់អំណាចសុទ្ធតែធ្វើការតតាំងគ្នាដោយអហឹង្សាគោរពគ្នាទៅវិញទៅមកពេលដែលគណបក្សមួយនិយាយ ទោះជាយើងពេញចិត្តមិនពេញចិត្តក្តីយើងស្តាប់ហើយញញឹមទទួលយក ។

លោក **លឿន តឹក** ជំទប់ទី២ ឃុំបេង មានចំងល់ទាក់ទងទៅនឹងផ្លាកសញ្ញារបស់គណបក្សនយោបាយ និងការឃោសនាបោះឆ្នោតតើត្រូវតែមានការសុំការអនុញ្ញាតពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ដែរ ឬ ទេ ?

លោក **ជិញ សំភូ** បានមានប្រសាសន៍ឆ្លើយតមនឹងសំនួរ លោក **ធឹង សំបាន** ថា ទាក់ទងទៅ នឹងទំរង់ ១០១៨ គឺ PEC ធ្វើឡើងទៅតាមច្បាប់ និងនិតិវិធីរបស់ គជប ដូច្នេះយើងមិនអាចកែប្រែច្បាប់បានទេ គឺការធ្វើទំរង់ ១០១៨ ធ្វើទៅបានលុះត្រាតែមានសាក្សី ២នាក់ ។ លោកបានបន្តទៀតថា នៅពេលដែលធ្វើទំរង់ ១០១៨ ពេលដែលប្រជាពលរដ្ឋធ្វើហើយត្រូវយករូបថតអោយមេឃុំ នៅពេលនោះពួកគាត់និយាយគ្នាអីយើងមិនបានដឹងទេ ដំណាក់កាលនេះមិនទាន់ដល់ដំណាក់កាលឃោសនាទេ ដូច្នេះបើសិន ជាគាត់ចង់ផ្តល់អំណោយ ឬ ក៏និយាយអ្វីបាន ព្រោះមិនទាន់ដល់ដំណាក់កាលហាមខាត់ទេ ។ ទាក់ទងទៅ នឹងចំងល់របស់ លោក **លឿន តឹក** ពាក់ព័ន្ធនិងផ្លាកសញ្ញារបស់គណបក្សនយោបាយ ពេលដែលត្រូវលើកផ្លាក PEC បានបង្រៀនគ្រប់គណបក្សគ្រប់អស់ ២ដង ហើយថាគ្រប់ផ្លាកសញ្ញារបស់គណបក្ស នយោបាយនៅពេលដែលលើកនៅទីសាធារណៈដាច់ខាតត្រូវតែសុំច្បាប់ដល់សមត្ថកិច្ចដែលមានការពាក់ព័ន្ធ ប៉ុន្តែបើសិនជាដាក់នៅផ្ទះរបស់ខ្លួនគ្រាន់តែធ្វើលិខិតជូនដំណឹងដល់អាជ្ញាធរទៅបានហើយ ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់ថា នៅពេលដែលគណបក្សទើបតែបង្កើត នៅពេលដែលយើងចុះបញ្ជីជាមួយក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការគណបក្សនោះកើតហើយ គឺច្បាប់បានធានានូវសកម្មភាពមួយចំនួនដោយមិនបាច់សុំច្បាប់ ពីអាជ្ញាធរឃុំទៀតទេគ្រាន់តែជូនដំណឹង ប៉ុន្តែសកម្មភាពមួយចំនួនត្រូវតែមានការសុំអនុញ្ញាត ដូចដែលលោកប្រធាន PEC បានមានប្រសាសន៍ នេះជាច្បាប់របស់គណបក្សនយោបាយដែលបានចែង ហើយចំពោះការឃោសនាបោះឆ្នោត និងនិតិវិធី គជប ក៏បានចែង

ច្បាស់នៅក្នុងនឹងដែរ គឺនៅជំពូកទី៨ បើយើងមើលហើយធ្វើទៅតាមនឹងមិនខុសទេ បើអាជ្ញាធរធ្វើខុសនឹងនិវិធី គឺខុសហើយអោយតែយើងមាននិតិវិធីនៅក្នុងដៃ ។

លោក **ឃុំ សុខុន** ដំណាងឃុំសំរោង សូមឱ្យបំភ្លឺបន្តិចទាក់ទង នឹងសាក្សី ប្រជាពលរដ្ឋខ្លះសាក្សីដែលមានទីលំនៅនៅក្បែរគ្នា ហើយផ្ទះរបស់គាត់នៅឆ្ងាយពីសាលាឃុំ អញ្ចឹងហើយលោកសំនូមពរអោយតែមេដៃសាក្សីមកសាលាឃុំបានដែរ ឬ អត់ ព្រោះដើម្បីកុំអោយរំខានដល់ការងាររបស់សាក្សីទាំងនោះ ។

លោក **ជិញ សំភូ** បានមានប្រសាសន៍ឆ្លើយតម ថាចំណុចនេះ លោក មិនអាចសំរេចបានទេព្រោះការពិនិត្យលើទំរង់ ១០១៨ នេះជាសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំទេ ។

លោក **ឱក សេរី សោភក្តិ៍** បាន់បញ្ជាក់ថា គណបក្សប្រជាជននៅពេលដែល ខប់សែល ប្រជុំនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ គណបក្សប្រជាជនមានការតិះតៀនពីគណបក្សផ្សេងៗ និងអង្គការសង្គមស៊ីវិលច្រើនណាស់ ប៉ុន្តែអ្វីដែល លោក បានឮពីតំណាងគណបក្សប្រជាជនមកចូលរួមប្រជុំនៅក្នុង ខប់សែល នឹងគាត់មានប្រសាសន៍ច្បាស់ថា សូមបែងចែកអោយច្បាស់រវាងអ្វីជាសកម្មភាពរបស់គណបក្ស និងអ្វីដែលជាសកម្មភាពរបស់បុគ្គល ដូច្នេះដើម្បីឆ្លើយតមនឹងសំនួរដែលគេនិយាយថា ទាល់តែបោះឆ្នោតអោយគណបក្សខ្ញុំទើបធ្វើទំរង់ ១០១៨ ខ្ញុំអោយ ហើយគាត់ជាសមាជិកក្រុមប្រឹក្សាភូមិ ដែលមិនដឹងថា គាត់មកពីគណបក្សណាទេ ប៉ុន្តែតាមតែ លោក បានឆ្លងកាត់ ២២ខេត្តមក រដ្ឋាភិបាលមានច្បាប់ទំលាប់ច្បាស់លាស់ ក៏ប៉ុន្តែ យើងសង្កេតឃើញថា នៅកន្លែងមួយចំនួនមានបុគ្គលិកខ្លះគាត់ស្រពិចស្រពិលគាត់ធ្វើទៅតាមករណីបុគ្គលមិនមែនជាលក្ខណៈទូទៅទេ បើបុគ្គលនោះធ្វើដូច្នេះគឺបុគ្គលនោះខុសហើយ ព្រោះសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ គឺដំណាងអោយរដ្ឋាភិបាលផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ហើយការធ្វើទំរង់ ១០១៨ នេះ គឺជាសេវារដ្ឋបាលដែលប្រជាពលរដ្ឋណាក៏ធ្វើបានដែរអោយតែចុះឈ្មោះបោះឆ្នោត លោក សូមសំណូមពរថា បើសិនជាបុគ្គលធ្វើសូមរាយការណ៏មក ទីន្លែងធ្វើខុស និងមុខដំណែងនោះ ខប់សែល នឹងរាយការណ៏ទៅ គ.ជ.ប និងក្រសួងមហាផ្ទៃ ហើយធ្វើការស៊ើបអង្កេតភ្លាម ដើម្បីជៀសវាងប៉ះពាល់ដល់អ្នកដទៃទៀតដែលគេធ្វើល្អ ។

លោក **ហង់ សាត** មេឃុំអន្លង់វែង បានលើកឡើងពីរចំនុច **ទី១** ទាក់ទងនៅ នឹងការចុះឈ្មោះបោះឆ្នោត និងការពិនិត្យឈ្មោះក្នុងបញ្ជីបោះឆ្នោត ក្នុងភាគីទាំងបីដែលបានស្រុះស្រួលគ្នាចុះឈ្មោះ និងធ្វើបែបបទ ១០១៨ ជូនប្រជាពលរដ្ឋ ដោយឡែកក៏មានការលំបាកមួយចំនួនដែរ ដោយបងប្អូនប្រជាពលរដ្ឋមួយចំនួនគាត់មិនយល់ពីការបោះឆ្នោត ដោយពួកគាត់ចូលទៅក្នុងព្រៃទោះបី ជាក្រុមការងាររបស់លោក ទៅរកគាត់ពីរបីលើកហើយនៅតែមិនជួបក្នុងករណីនេះធ្វើឱ្យអាក់ខានមិនបានចុះឈ្មោះបោះឆ្នោត ។ ទី២ បញ្ហាថ្ងៃធ្វើការឃោសនាបោះឆ្នោត ផ្លាកគណបក្សរបស់គេដាក់នៅថ្នល់ខាងក្រោយ ឯផ្លាកគណបក្សរបស់ លោក ដាក់នៅថ្នល់ខាងមុខ ពេលនោះមានខ្យល់ព្យុះ និងភ្លៀងធ្វើឱ្យផ្លាកគណបក្សរបស់គេម្ខាងទៀតធ្លាក់មកដី ឯផ្លាកគណបក្សរបស់ លោក ក៏ធ្លាក់មកលើដីដែរ ហើយគណបក្សម្ខាងទៀតបានទៅប្តឹង គ.ជ.ប ថា គណបក្សប្រជាជនបានទៅទម្លាក់ផ្លាកគណបក្សរបស់គេ លោក ក៏បានស្រាយបំភ្លឺថា បើផ្លាកគណបក្សម្ខាងទៀតធ្លាក់ថា គណបក្សប្រជាជនទំលាក់ តើផ្លាកគណបក្សប្រជាជនអ្នកណាជាអ្នកទម្លាក់ ?

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៍ថា បើសិនជាមានការធ្លាក់ផ្លាកសញ្ញាគណបក្ស សូមពិនិត្យមើលអោយបានច្បាស់លាស់ឈប់ចោទប្រកាន់ដាក់គ្នាទៅ ។ លោក បានសំណូមពរទៅលោកស្រី **អ៊ឹម ចែម** មេឃុំត្រពាំងតាវថា ថ្ងៃក្រោយសូមកុំភ្នាល់គ្នាវាយទំលាក់ផ្លាកសញ្ញាគណបក្សធ្វើអ្វីគួរតែភ្នាល់គ្នារឿងផ្សេងវិញ ។

លោក **ឡា ប៊ុនហាន** មន្ត្រីគ្រប់គ្រងគំរោង CARE បានមានប្រសាសន៏ទាក់ទង នឹងការអភិវឌ្ឍន៏ខ្លះ ឃុំជាស្ថាប័នមួយជាអង្គភាពមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាទូទៅសំរាប់សំរួលការអភិវឌ្ឍន៏នៅក្នុងឃុំ ពាក់ព័ន្ធនឹងជំនួយរបស់គំរោងអភិវឌ្ឍភូមិភាគពាយព្យដែលធ្វើលើ ៤ខេត្ត ដែលមានក្រុមព្រឹក្សាឃុំ ប្រហែល ៤៦ឃុំ ដែលទាក់ទង នឹងគំរោងអភិវឌ្ឍភូមិភាគពាយព្យ លោក បានសួរថា តើការរៀបចំការបោះឆ្នោតឃុំ-សង្កាត់ នៅខែមេសាខាងមុខនេះ មានប៉ះពាល់ដល់ដំណើរការផ្សេងៗ ដូចជាការធ្វើវិនិយោគពាក់ព័ន្ធនឹងការអភិវឌ្ឍ ។

លោក **ជិញ សំភូ** បានមានប្រសាសន៏ថា រាល់បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងអង្គប្រជុំនេះ លោក បានកត់ទុក ហើយធ្វើការពិចារណា ក៏ដូចជាធ្វើការតាមដានស្រាវជ្រាវរករាល់កំហុសឆ្គង PEC នឹងចាប់ផ្តើមកែប្រែ នឹងធ្វើលិខិតជូនគ្រប់គណបក្សនយោបាយ អាជ្ញាធរដែនដី ។ លោក ក៏សូមថ្លែងអំណរគុណនូវការយកចិត្តទុកដាក់ស្តាប់ លោក សង្ឃឹមថា គណបក្សនយោបាយប្រចាំខេត្តជួយណែនាំបន្ថែមដល់សាខាបក្សរបស់ខ្លួននៅតាមឃុំ ។ លោក បានជំរាបថា ការរៀបចំការបោះឆ្នោតចំនួន ៥លើក កន្លងមក តាមរបាយការណ៏បូកសរុបខេត្តឧត្តរមានជ័យទទួលបានចំណាត់ថ្នាក់លេខ ២ ទូទាំងប្រទេស ដូច្នេះ លោក សង្ឃឹមថា ការបោះឆ្នោតនៅថ្ងៃទី១ ខែមេសា ខាងមុខនេះខេត្តឧត្តរមានជ័យកាន់តែមានភាពល្អប្រសើរ ដោយសារតែគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធដែលបានរក្សាស្ថេរភាព-សុវត្ថិភាព នៃការបោះឆ្នោត ហើយ លោក សង្ឃឹមថា ខប់សែលប្រ៉ម នឹងមកធ្វើជាលើកទី ២ ក្នុងខេត្តឧត្តរមានជ័យនេះ ។

លោក **ឱក សេរី សោភក្តិ៍** បានសន្យាថា នឹងមកធ្វើកិច្ចប្រជុំនៅខេត្តឧត្តរមានជ័យម្តងទៀតមុនពេលបោះឆ្នោតថ្នាក់ជាតិ លោក បានយល់ស្របទៅនិងមតិយោបល់របស់ លោក **ឡា ប៊ុនហាន** មន្ត្រីគ្រប់គ្រងគំរោង CARE លោកយល់ថា គំរោងអភិវឌ្ឍឃុំទាំង ៤៦នេះ ជារឿងមួយសំខាន់ ហើយរដ្ឋាភិបាលក៏បានដាក់ក៏រិតថា ទោះបីមាន ឬគ្មានការរៀបចំការបោះឆ្នោតក៏ដោយ ម៉ោងធ្វើការមិនមានពាក់ព័ន្ធទេត្រូវតែបំពេញតួនាទីរបស់ខ្លួន បំពេញគ្រប់ទាំងអស់ ដូចជា សេវាកម្មរដ្ឋបាល សេវាការអភិវឌ្ឍ នៅពេលចប់ម៉ោងធ្វើការបានធ្វើអ្វីធ្វើចុះ ។

លោក **ឌួង វីរ័ត្ន** មានចំណាប់អារម្មណ៏ពីរ **ទី១** សូមកោតសរសើរចំពោះការលើកឡើងរបស់អង្គប្រជុំទាំងមូល ដែលបានលើកឡើងប្រកបដោយសេចក្តីថ្លៃថ្នូរ និងច្បាស់លាស់ប្រកបទៅដោយអត្ថន័យ ។ **ទី២** នៅឆ្នាំ ២០០១-២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជាបានចុះមកធ្វើការយ៉ាងយូរជាមួយឃុំឯទៀតក្នុងការបណ្តុះបណ្តាលនោះ តាមរបាយការណ៏របស់លោក ប្រធាន PEC ខេត្តឧត្តរមានជ័យមានការសហការគ្នាល្អណាស់ និងលើសពីស្រុកឯទៀតៗ ទាំងអស់នេះអាចជាគំរូសំរាប់ទីកន្លែងឯទៀតៗក្នុងការងារបោះឆ្នោត និងការកសាងសន្តិភាព ក្នុងនាម លោក តំណាងឱ្យ លោក **ឡារី ស្រ្តេន្ទ** សូមថ្លែងអំណរគុណដល់អង្គប្រជុំទាំងមូលដែលបានចំណាយពេលវេលាដ៏មានតំលៃចូលរួមក្នុងអង្គប្រជុំនេះ ហើយជាពិសេសសូមថ្លែងអំណរគុណដល់ លោក **ជិញ សំភូ** ដែលបានចំណាយពេលដ៏មានតំលៃរៀបចំឯកសារសំរាប់កិច្ចប្រជុំនេះ ព្រមទាំងសូមថ្លែងអំណរគុណដល់ ឯកឧត្តមអភិបាលខេត្ត ដែលបានអនុញ្ញាតអោយវិទ្យាស្ថាន CDRI បានរៀបចំកិច្ចប្រជុំនេះឡើង ។ លោក ក៏សូមថ្លែងអំណរគុណដល់លោកប្រធានមន្ទីរអបរំ យុវជន និងកីឡាខេត្តឧត្តរមានជ័យដែលបានផ្តល់ជាកន្លែងសំរាប់កិច្ចប្រជុំនេះ និងសូមថ្លែងអំណរគុណដល់លោក **ឱក សេរី សោភក្តិ៍** ដែលបានធ្វើការសំរបសំរួលបានយ៉ាងប៉ិនប្រសប់ក្នុងកិច្ចប្រជុំនេះ ព្រមទាំងក្រុមការងារ ខប់សែល ទាំងអស់ ហើយក៏សូមថ្លែងអំណរគុណផងដែរដល់ UNDP ដែលបានគាំទ្រយ៉ាងពេញទំហឹងចំពោះយន្តការខប់សែល ដែលបានផ្តល់ជាថវិការសំរាប់កម្មវិធីនេះ ។

លោក **ឱក សេរី សោភក្តិ៍** បានមានប្រសាសន៏ថា អង្គប្រជុំមួយព្រឹកនេះបានបង្ហាញនូវអាកប្បកិរិយា និងប្រសាសន៏ដ៏ថ្លៃថ្លា ដែលវាលគ្មិនបានលើកឡើង ទាំងអស់នេះជាការកសាងវប្បធមិសន្តិភាពមួយថ្មីនៅក្នុងសង្គមកម្ពុជាទាំងមូល ហើយខេត្តឧត្តរមានជ័យ អន្លង់វែង ស្រុកត្រពាំងប្រាសាទ និងមានឃុំផ្សេងៗ ទៀតដែលចំណុះអោយខេត្តឧត្តរមានជ័យជាខេត្តមួយដែលជាចំណុចក្តៅដែល ត្រូវបានប្រែពីតំបន់ដែលមានសង្គ្រាមក្លាយជាតំបន់ដែលមានការអភិវឌ្ឍន៏ដ៏ស្រស់បំព្រង ។